មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស
CENTER FOR ALLIANCE OF LABOR AND HUMAN RIGHTS
ផ្ទះលេខ៣៥៩ ផ្លូវលេខ ៦៩Rd ខណ្ឌចំការមន រាជធានីភ្នំពេញ #359 street 69Rd, Phnom Penh
០៩៣ ៥៥៦៦០៣ អ៊ីម៉ែល info@central-cambodia.org - Website www.central-cambodia.org

# សេចក្តីប្រកាសព័តមាន

កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ លោក **មឿន តុលា** នាយកមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស បានទទួលដីកាលើកលែងការចោទប្រកាន់ លើករណីបណ្តឹងរបស់ឈ្មោះ ពេជ្រ ស្រស់ ប្រធានគណបក្សយុវជនកម្ពុជាដែលបានប្តឹងចូលអយ្យការសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ អំពីករណីប្រាក់បច្ច័យបានមកពីការចូលបុណ្យសពលោក បណ្ឌិត **កែម ឡី** ។

ក្រោយពីបានឆ្លងកាត់នូវនីតិវិធីស៊ើបអង្កេត និងនីតិវិធីស៊ើបសួរតុលាការរាជធានីភ្នំពេញ បានសម្រេចលើកលែងចោទប្រកាន់ដោយហេតុថា គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើលោក **មឿន តុលា** ។

សេចក្តីសម្រេចខាងលើនេះ គឺជាផលជាវិជ្ជមានដល់មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ក្នុងការបន្តបំពេញបេសកម្មរបស់ខ្លួន ដើម្បីលើកកម្ពស់សិទ្ធិការងារ និងសិទ្ធិមនុស្ស នៅប្រទេសកម្ពុជា។ ជាមួយគ្នានេះផងដែរ យើងខ្ញុំសង្ឃឹមថានឹងមានសេចក្តីសម្រេចវិជ្ជមានបែបនេះបន្តទៀត នៅក្នុងសំណុំរឿងព្រហ្មទណ្ឌដទៃទៀតដែលអ្នកការពារសិទ្ធិមនុស្ស និងអ្នកការពារសិទ្ធិកម្មករផ្សេងទៀតកំពុងជាប់បណ្តឹងព្រហ្មទណ្ឌនៅតុលាការនៅឡើយ ។

មជ្ឈមណ្ឌលសម្ព័នភាពការងារ និងសិទ្ធិមនុស្ស ប្តេជ្ញាចិត្តបន្តបេសកម្មរបស់ខ្លួនក្នុងការលើកម្ពស់ សិទ្ធិការងារ និងសិទ្ធិមនុស្សនៅប្រទេសកម្ពុជាតាមរយៈពង្រឹងសមត្ថភាពកម្មករ ផ្តល់ជំនួយផ្នែកច្បាប់ និងមធ្យោបាយសមស្របដទៃទៀត។

ព័ត៌មានបន្ថែម សូមទាក់ទង លោក ឃុន ថារ៉ូ ០៩៣ ៥៥ ៦៦ ៧១ អ្នកសម្របសម្រួលកម្មវិធី

*ថ្ងៃព្រហស្បតិ៍ ១៥រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦១*
*រាជធានីភ្នំពេញ. ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨*